00867310

002/19-09-2007-ECCC/TC
E1/136

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 11 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២២ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១២៣

រៀបចំដោយ: ដាវ អានសាន និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Roger PHILLIPS, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ តារាវុឌ្ឍ, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក សំ សុគង់, លោក ឡោ ជុនធី, លោកស្រី ទី ស្រ៊ីនណា, លោក ហុង គីមសួន, លោក វ៉ែន ពៅ |
| អ្នកផ្តល់សក្ខីកម្ម៖ ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ (TCCP-169) និង ជុំ សុខា (TCCP-25) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក Jay GALIK |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.១០ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២០ | បញ្ចប់ម៉ោង៖ ១០.៤៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង និង ៥៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សម្រេចលើការលះបង់សិទ្ធិចូលរួមសវនាការ | អង្គជំនុំជម្រះ | ៩.០៨ | ៩.០៨ |
| សំណើសុំថ្លែងអំពីព្យសនកម្មទាំងមូល | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.០៨ | ៩.៤៨ |
| សម្រេចលើសំណើសុំថ្លែងអំពីព្យសនកម្មទាំងមូល | អង្គជំនុំជម្រះ | ៩.៤៩ | ៩.៥១ |
| ការថ្លែងសេចក្តីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 និងការកត់សម្គាល់របស់ភាគីលើសេចក្តីថ្លែង | ដើមបណ្តឹងរដ្ឋប្បវេណី<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ៩.៥២<br>១០.០៤<br>១០.០៦<br>១០.០៨ | ១០.០៤<br>១០.០៦<br>១០.០៨<br>១០.១១ |
| សំណើលើការកត់សម្គាល់លើសេចក្តីថ្លែងរបស់ដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណី | សហព្រះរាជអាជ្ញា | ១០.១១ | ១០.១៧ |

| | | | |
|---|---|---|---|
| ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី TCCP-25 | អង្គជំនុំជម្រះ<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>មេធាវី នួន ជា<br>មេធាវី អៀង សារី<br>មេធាវី ខៀវ សំផន | ១០.៤៧<br>១០.៥០<br><br>១៥.០៤<br>១៥.៤៧<br>១៥.៤៨<br>១៥.៤៨ | ១០.៤៩<br>១៤.៤០<br><br>១៥.៤៧<br>១៥.៤៧<br>១៥.៤៨<br>១៥.៤៩ |
| ការសម្រេចលើសេចក្ដីជំទាស់ស្ដីពីភាពពាក់ព័ន្ធ លើកឡើងដោយមេធាវី នួន ជា | អង្គជំនុំជម្រះ | ១១.៥៣ | ១១.៥៤ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្ដី នួន ជា | ១២.០៧ | ១២.០៧ |
| ការថ្លែងអំពីទុក្ខវេទនារបស់ TCCP-25 | ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-25 | ១៥.៤៩ | ១៦.១៦ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សម្រេចលើការលះបង់សិទ្ធិចូលរួមសវនាការ**

ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិចូលរួមសវនាការចំពោះការស្ដាប់សក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ (TCCP-169) និង ជុំ សុខា (TCCP-25)។

**សំណើសុំថ្លែងអំពីព្យសនកម្មទាំងមូល**

មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ថ្លែងអំពីព្យសនកម្ម និងសេចក្ដីទុក្ខសោករបស់ពួកគេ ក្នុងវិសាលភាពនៃសំណុំរឿង ០០២ ទាំងមូល ជាជាងកំណត់ត្រឹមតែការថ្លែងក្នុងក្របខណ្ឌនៃសំណុំរឿងដំណាក់កាលទី១ ០០២/០១។

**<u>ការសម្រេចលើសំណើសុំថ្លែងអំពីព្យសនកម្មទាំងមូល</u>**

ក្រោយការពិភាក្សាដេញដោលលើសំណើសុំនេះ អង្គជំនុំជម្រះ សម្រេចអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 ថ្លែងអំពីសេចក្តីទុក្ខសោកទាំងមូលរបស់ខ្លួន ដែលបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់សំណើដូច្នេះជាលាយលក្ខណ៍អក្សរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ហើយសេចក្តីសម្រេចនាពេលនេះត្រូវអនុវត្តរហូតមានការសម្រេចជាលាយលក្ខណ៍អក្សរពីអង្គជំនុំជម្រះសាលាដំបូង។

**<u>ការថ្លែងសេចក្តីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ TCW-169</u>**

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 អានព្យសនកម្ម និងសេចក្តីទុក្ខសោក ជូនអង្គសវនាការ។ ជាបន្តបន្ទាប់ក្រុមមេធាវីការពារក្តី និងភាគីទាំងអស់បានផ្តល់ការយល់ឃើញលើសេចក្តីថ្លែង និងបានសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

**<u>សំណើលើការកត់សម្គាល់លើសេចក្តីថ្លែងរបស់ដើមបណ្តឹងបណ្តឹងរដ្ឋប្បវេណី</u>**

សហព្រះរាជអាជ្ញាបានស្នើថា ក្រុមការពារក្តីមិនត្រូវធ្វើការកត់សម្គាល់ណាមួយចំពោះសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ គប្បីឱ្យគាត់ចាកចេញពីបន្ទប់សវនាការជាមុនសិន។

**<u>ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី TCCP-25</u>**

អង្គជំនុំជម្រះចាប់ផ្តើមសួរដើមបណ្តឹងប្បវេណីរូបនេះ ហើយផ្តល់វេទិកាទៅ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសាកសួរ។ កិច្ចសាកសួរបានបន្តដោយសហព្រះរាជអាជ្ញា និងជាបន្តបន្ទាប់ដោយក្រុមមេធាវីការពារក្តី។

**<u>ការថ្លែងអំពីទុក្ខវេទនា</u>**

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-25 ត្រូវបានផ្តល់ឱកាសថ្លែងនូវព្យសនកម្ម និងទុក្ខសោកដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មិនមានការកត់សម្គាល់ណាមួយត្រូវបានធ្វើឡើងចំពោះសេចក្តីថ្លែងទុក្ខវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើយ។

**សេចក្តីសម្រេចផ្ទាល់មាត់**

អង្គជំនុំជម្រះសម្រេចថា សក្ខីកម្មដែលផ្តល់ដោយសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តោតជាសំខាន់ស្ថិតនៅក្នុងវិសាលភាពនៃសវនាការ សំណុំរឿង ០០២/០១។ ការពណ៌នា ឬការផ្តល់សក្ខីកម្មក្រៅវិសាលភាពគប្បីត្រូវកំហិតឲ្យបានតិចជាអប្បបរមា។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ នួន ជា (ម៉ោង ១២.០៧) តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/3953 | D22/110.1 | 00359558-00359683 | ឧបសម្ព័ន្ធ ១៖ រឿង នរកលោកីយ៍ ក្នុងសម័យ ប៉ុល ពត ភាគទី១ | P | | | |
| E3/3954 | D22/110.2 | 00359684-00359810 | ឧបសម្ព័ន្ធ ២៖ រឿង នរកលោកីយ៍ ក្នុងសម័យ ប៉ុល ពត ភាគទី២ | P | 00359684-698 | | |
| E3/3955 | D22/110.3 | 00359811-00359880 | ឧបសម្ព័ន្ធ ៣៖ រឿង នរកលោកីយ៍ ក្នុងសម័យ ប៉ុល ពត ភាគទី៣ ចប់ | P | | | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា (១២.០៧) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ពេលរសៀល និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីតុលាការនាំដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 និង TCCP-25 ត្រឡប់ទៅគោលដៅរបស់ខ្លួនវិញ ព្រោះការផ្តល់សក្ខីកម្មរបស់ពួកគេបានបញ្ចប់ហើយ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩.០០ ព្រឹក ថ្ងៃអង្គារ ទី ២៣ ខែ តុលា ឆ្នាំ ២០១២។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| **សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ២៣ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។** |

**ភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២**

**ក្រឡាបញ្ជី ក្រឡាបញ្ជី**

**ដាវ [illegible]** Roger PHILLIPS